## ឧបសម្ព័ន្ធ (៤), ទម្រង់ប្រកាសលក្ខខណ្ឌនៃការដេញថ្លៃ

ទម្រង់ប្រកាសនេះមានសារសំខាន់ណាស់ សម្រាប់អ្នកចូលរួមដេញថ្លៃទាំងអស់ ព្រោះទម្រង់នេះត្រូវបានកំណត់សម្រាប់***វាយតម្លៃជ្រើសរើសអ្នកម៉ៅការ និងជាឧបសម្ព័ន្ធនៃកិច្ចសន្យា*** ផងដែរ ដូច្នេះអ្នកដេញថ្លៃទាំងអស់ត្រូវ***អានឱ្យបានច្បាស់លាស់ មុននឹងឆ្លើយ*** បាន/យល់ព្រម ឬមិនបាន/មិនយល់ព្រម តាមលក្ខខណ្ឌនៃការដេញថ្លៃនេះ ។

| លរ | បរិយាយ | បាន/ឯកភាព | មិនបាន/មិនឯកភាព |
|---|---|---|---|
| | **លក្ខខណ្ឌទូទៅ** | | |
| 1. | តើអ្នកបានអានលម្អិត យល់ច្បាស់ និងឯកភាពទាំងស្រុងនូវលក្ខខណ្ឌទាំងអស់ នៃ**ឯកសារសំខាន់ៗ** តាមទម្រង់ដើម ឬច្បាប់ចម្លងពិតប្រាកដនៃទម្រង់ដើម របស់ឯកសារដេញថ្លៃ ខាងក្រោមជាឧបសម្ព័ន្ធ នៃកិច្ចសន្យាពេលដែលអ្នកទទួលបានជោគជ័យក្នុងការដេញថ្លៃ ដែរ ឬទេ?<br>- សំណើសុំចូលរួមដេញថ្លៃ<br>- សេចក្តីប្រកាសក្រមសីលធម៌វិជ្ជាជីវៈ<br>- ការណែនាំសម្រាប់អ្នកចូលរួមដេញថ្លៃ<br>- លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ<br>- លក្ខខណ្ឌទូទៅនៃកិច្ចសន្យា<br>- ឧបសម្ព័ន្ធ(១)បទដ្ឋានបច្ចេកទេស និងលក្ខណៈបច្ចេកទេសលម្អិតនៃសម្ភារ និងការប្រើប្រាស់ឧបសម្ព័ន្ធ(២)គំនូសប្លង់<br>- ឧបសម្ព័ន្ធ(៣) បញ្ជីវាយចំណាយលើសម្ភារ និងពលកម្ម (BoQ) និងបញ្ជីទូទាត់ចំណាយតាមដំណាក់កាល<br>- ឧបសម្ព័ន្ធ(៤) ទម្រង់ប្រកាសលក្ខខណ្ឌនៃការដេញថ្លៃ (ទម្រង់ប្រកាសកំពុងអាននេះស្រាប់) | ☐ | ☐ |
| 2. | តើអ្នកដឹងទេថា ប្រសិនបើក្នុងបញ្ជីវាយចំណាយលើសម្ភារ និងពលកម្ម (BoQ) មិនបានបង្ហាញបរិមាណការងារមួយចំនួន ប៉ុន្តែមានក្នុងគំនូសប្លង់ ឬបទដ្ឋានបច្ចេកទេស លក្ខណៈបច្ចេកទេសលម្អិតនៃសម្ភារ ឬកិច្ចសន្យា ឬក្នុងឧបសម្ព័ន្ធណាមួយនៃកិច្ចសន្យា អ្នកត្រូវអនុវត្តការងារនេះ ដោយឥតលក្ខខណ្ឌ? | ☐ | ☐ |
| 3. | តើអ្នកដឹងទេថា ករណីមានការរៀបរាប់ការងារណាមួយជាន់គ្នាចំពោះការងារតែមួយក្នុងឯកសារដេញថ្លៃ អ្នកអាចជ្រើសរើស ឬកែតម្រូវក្នុងកំឡុងពេលដេញថ្លៃមុនបាន ដើម្បីអង្គការសម្រេច តែករណីអ្នកមិនកែតម្រូវក្នុងពេលដេញថ្លៃ ការកំណត់ជ្រើសរើសការងារនោះសម្រាប់អនុវត្ត គឺអាស្រ័យដោយអង្គការជាអ្នកកំណត់ ? | ☐ | ☐ |
| | **<u>ចុះត្រួតពិនិត្យទីតាំងគម្រោងជាក់ស្តែងដើម្បីដាក់តម្លៃ</u>** | | |
| 4. | តើអ្នកបានចុះត្រួតពិនិត្យទីតាំងគម្រោង, បានវិភាគហានិភ័យ, តម្រូវការទូទៅនៅលើទីតាំងគម្រោងជាក់ស្តែងទាំងអស់, ដើម្បីអនុវត្តការងារទាំងមូលក្នុងឯកសារដេញថ្លៃ ទៅតាមផែនការ កាលវិភាគ, បញ្ជីវាយចំណាយលើសម្ភារ និងពលកម្ម (BoQ) ធៀបនឹងគំនូសប្លង់ និងរួមបញ្ចូលរាល់វិបត្តិបញ្ហាទាំងអស់ បញ្ចូលក្នុងតម្លៃដេញថ្លៃរបស់អ្នក មុនពេលដាក់មកអង្គការដើម្បីវាយតម្លៃដែរឬទេ? | ☐ | ☐ |
| | **<u>ការរៀបចំកាលវិភាគ</u>** | | |
| 5. | តើអ្នកដឹងទេថា ការបញ្ចប់គម្រោងទាំងមូល អ្នកមានរយៈពេល **២១០ថ្ងៃ នៃថ្ងៃប្រតិទិន** (ដោយរាប់ទាំងថ្ងៃសៅរ៍, ថ្ងៃអាទិត្យ, ថ្ងៃឈប់សម្រាកសាធារណៈ, ហានិភ័យពេលរដូវវស្សា, ហានិភ័យក្នុងការផ្គត់ផ្គង់សម្ភារ, ហានិភ័យកម្លាំងពលកម្មមិនគ្រប់គ្រាន់, ហានិភ័យក្នុងការចំណាយពេលវេលាច្រើនក្នុងកិច្ចការណាមួយ, ពិធីសង្គម និងពិធីផ្សេងៗ)? | ☐ | ☐ |
| 6. | **<u>ម៉ោងធ្វើការរបស់ម្ចាស់គម្រោង</u>** | | |
| 7. | តើអ្នកបានដឹងទេថា ថ្ងៃធ្វើការរបស់អង្គការ ចាប់ពីម៉ោង ៧:៣០ ព្រឹក ដល់ម៉ោង ១២:០០ ថ្ងៃត្រង់ និងពីម៉ោង ១:០០ រសៀល ដល់ម៉ោង ៤:៣០ រសៀល ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ មិនរាប់បញ្ចូល ជាមួយថ្ងៃសៅរ៍ អាទិត្យ និងថ្ងៃឈប់សម្រាកសាធារណៈទេ? ដូច្នេះអ្នកឯកភាពថា អ្នកនឹងដោះស្រាយបញ្ហានានា ក្នុងម៉ោងធ្វើការរបស់អង្គការឱ្យបានត្រឹមត្រូវ ? | ☐ | ☐ |
| | **<u>កម្លាំងពលកម្ម, ឧបករណ៍-សម្ភារ និងគ្រឿងចក្រ</u>** | | |
| 8. | តើអ្នកមានបុគ្គលិក កម្មករ កម្មករជំនាញ ឧបករណ៍-សម្ភារ គ្រប់គ្រាន់សម្រាប់ការអនុវត្តគម្រោងនេះទេ? | ☐ | ☐ |
| 9. | តើអ្នកដឹងថា អ្នកត្រូវបង្ហាញតារាងអ្នកទទួលខុសត្រូវ និងចំនួនកម្មករនៅការដ្ឋាន, រាល់ការផ្លាស់ប្តូរ និងការជំនួសបុគ្គលិក កម្មករ កម្មករជំនាញនៅការដ្ឋាន ត្រូវបានជូនដំណឹង និងស្នើសុំការយល់ព្រមពីអង្គការ, ហើយអ្នកត្រូវព្រមព្រៀងថា អ្នកត្រូវមានអ្នកគ្រប់គ្រងប្រចាំការនៅការដ្ឋានពេញម៉ោង ដើម្បីត្រួតពិនិត្យការងារ ទូទៅ, សុខភាព និងសុវត្ថិភាព, បច្ចេកទេស និងរៀបចំរបាយការណ៍ប្រចាំថ្ងៃជូនអង្គការ, ករណីមានបុគ្គលិកបរទេស អ្នកត្រូវធានាថា គាត់គោរពតាមច្បាប់ការងារ កម្ពុជា ការរស់នៅស្របច្បាប់ ដែលត្រូវមានការអនុញ្ញាតពីអាជ្ញាធរ ? | ☐ | ☐ |
| | **<u>តម្លៃ</u>** | | |

| | | | |
|---|---|---|---|
| 10. | - តើអ្នកឯកភាពទេ តម្លៃ នៃគម្រោងនេះ គឺអ្នកទទួលខុសត្រូវយ៉ាងពេញលេញអំពីកាតព្វកិច្ចក្នុងការសាងសង់ ឱ្យបញ្ចប់ការងារទាំងអស់ នៃកិច្ចសន្យា ?<br>- តើអ្នកឯកភាពទេ តម្លៃក្នុង BoQ គឺរួមបញ្ចូលទាំងថ្លៃពន្ធ, ថ្លៃដឹកជញ្ជូន, សម្ភារ-ឧបករណ៍ប្រើប្រាស់,ថ្លៃរបៀបចំ ចំណាយប្រចាំខែ ប្រព័ន្ធទឹក អគ្គិសនីសម្រាប់ប្រើប្រាស់បណ្តោះអាសន្ន និងថ្លៃហានិភ័យផ្សេងៗដូចជា អតិផរណា កង្វះខាតកម្មករ ជាដើម?<br>- តើអ្នកឯកភាពទេថា បរិយមាណក្នុង BoQ គឺជាបរិមាណដែលអ្នកបានវាស់វែង នឹងផ្ទៀងផ្ទាត់ជាក់ស្តែង ករណីមានចំណុចខ្វះខាតណាមួយ អ្នកមិនអាចស្នើសុំចំណាយបន្ថែមពីអង្គការបានទេ?<br>- តើអ្នកឯកភាពទេ ថាផលិតផលទាំងអស់ត្រូវបានផ្គត់ផ្គង់ ជាផលិតផលថ្មី ស្របច្បាប់ និងស្របតាមច្បាប់ផលិតផលរបស់ប្រទេសនីមួយៗ (Right Channel) និងអាចប្រើប្រាស់បានតាមតម្រូវការរបស់អង្គការ ។ ប្រសិនបើ អង្គការ បានត្រួតពិនិត្យឃើញផលិតផលខុស (Wrong Channel) ឬមិនយកផលិផលដែលមានការឯកភាពគំរូចុងក្រោយដែលបានផ្តល់ជូន អ្នកម៉ៅការត្រូវប្តូរថ្មីជូនអង្គការ និងទទួលការផាកពិន័យ ១០% នៃចំនួនសរុបនៃកិច្ចសន្យា រួមទាំងរក្សាពេលវេលាសាងសង់នៅដដែល ដោយឥតលក្ខខណ្ឌ ?<br>- តើអ្នកឯកភាពទេ ប្រសិនបើផលិតផលដែលបានចុះកិច្ចសន្យាហួសកាលបរិច្ឆេទប្រើប្រាស់, អ្នកផ្គត់ផ្គង់ត្រូវផ្លាស់ប្តូរផលិតផលថ្មី ឱ្យមានគុណភាពខ្ពស់សមស្របជាមួយនឹងបច្ចេកទេស, រក្សាតម្លៃឱ្យនៅដដែល ឬកែប្រែតម្លៃក្នុងកិច្ចសន្យា ប្រសិនបើតម្លៃនៅលើទីផ្សារទាបជាង?<br>- តើអ្នកដឹងទេថា អ្នកមិនត្រូវអនុញ្ញាតឱ្យលក់ការដេញថ្លៃទាំងមូល ឬផ្លាស់ប្តូរទៅឱ្យអ្នកទទួលការផ្សេងទៀតទេ? | ☐ | ☐ |
| | <u>**លក្ខខណ្ឌទូទាត់**</u> | | |
| 11. | តើអ្នកដឹងទេថា ការទូទាត់ប្រាក់ ត្រូវធ្វើឡើងបន្ទប់ពីអ្នក បានបញ្ចប់ការងារតាមដំណាក់កាលដែលកំណត់ក្នុងឧបសម្ព័ន្ធ , មានការឯកភាពពីអង្គការ និងក្រោយ ប្រាំពីរ (០៧)ថ្ងៃបន្ទាប់ពីទទួលបានវិក័យបត្រច្បាប់ដើមពីអ្នក? | ☐ | ☐ |
| | <u>**តម្លៃចំណាយបន្ថែម**</u> | | |
| 12. | តើអ្នកដឹងទេថា ការស្នើសុំទឹកប្រាក់សម្រាប់រៀបចំការងារបន្ថែម (ថ្មី) ក្រៅពីឯកសារកិច្ចសន្យា គឺត្រូវមានការព្រមព្រៀងដោយអង្គការជាមុនសិន មុននឹងអ្នកចាប់ផ្តើមធ្វើការងារនោះ ហើយករណីអ្នកធ្វើរួចមុនពេល ឯកសារអនុមតិ អង្គការនឹងបដិសេធ ហើយអ្នកនឹងទទួលខុសត្រូវចំពោះការចំណាយនូវតម្លៃការងារទាំងនោះ? | ☐ | ☐ |
| | <u>**រយៈពេលធានា**</u> | | |
| 13. | តើអ្នកឯកភាពទំនួលខុសត្រូវលើជួសជុល ការធានា និងការថែទាំ រយៈពេល ១២ខែ បន្ទាប់ពីការចេញលិខិតបញ្ចប់គម្រោងទាំងមូលទេ? | ☐ | ☐ |
| | <u>**ការគ្រប់គ្រងគុណភាព**</u> | | |
| 14. | តើអ្នកដឹងទេថា រាល់ការងារទាំងអស់ត្រូវតែមានគុណភាព ស្របតាមឯកសារទាំងអស់នៃកិច្ចសន្យា ដោយអ្នកត្រូវត្រួតពិនិត្យជាប្រចាំ, មុននឹងស្នើសុំអង្គការត្រួតពិនិត្យ អ្នកត្រូវត្រួតពិនិត្យដោយផ្ទាល់ឱ្យបានគ្រប់ជ្រុងជ្រោយជាមុនសិន ករណីអង្គការរកឃើញថា ការងារណាមួយមិនត្រឹមត្រូវ ឬមិនមានគុណភាពអង្គការ មានសិទ្ធមិនទទួលយក និងអ្នកត្រូវធ្វើការងារនោះឡើងវិញដោយឥតលក្ខខណ្ឌ? | ☐ | ☐ |
| 15. | តើអ្នកដឹងទេថា អ្នកត្រូវរៀបចំឱ្យមានឧបករណ៍-សម្ភារសម្រាប់គាំទ្រដល់ការងារចុះ<u>ការត្រួតពិនិត្យរាល់ពេលបញ្ចប់ការងារនីមួយៗតាមដំណាក់កាល</u> ឱ្យបានគ្រប់គ្រាន់ ដូចជារៀបចំជណ្តើរ, ប្រដាប់ប្រដាសម្រាប់បាញ់ទឹកតេស្តដំបូល ឬទុ-ទឹក ឬឧបករណ៍-សម្ភារផ្សេងៗតាមតម្រូវការ និងស្ថានភាពនៃត្រួតពិនិត្យ? | ☐ | ☐ |
| 16. | <u>**ការលាបថ្នាំផ្នែកខាងក្រៅ និងខាងក្នុង**</u><br>តើអ្នកដឹងទេថា អ្នកត្រូវទទួលខុសត្រូវចំពោះគុណភាព នៃ បេតុង បូក បៀក និងការលាបថ្នាំ? ដោយត្រូវអនុវត្តតាមជំហានដូចខាងក្រោម?<br>- ការងារបេតុង ឬការងារបូក ត្រូវបញ្ចប់ចុងក្រោយ ជាមួយផ្ទៃរលោង ត្រង់ ស្មើបញ្ឈរ ឬផ្ដេក ដោយមិនមានការរមួល ឬបត់បែន។<br>- ភាពរលោងដោយសីបាយអ<br>- សម្អាតលើផ្ទៃជញ្ជាំងឱ្យបានស្អាត<br>- បៀកថ្នាំទ្រនាប់<br>- លាបថ្នាំទ្រនាប់<br>- លាបថ្នាំសម្រេច តាមផ្ទៃជញ្ជាំងខាងក្រៅ និងខាងក្នុង។<br>- ការលាបថ្នាំទាំងអស់ត្រូវលាបតាមការណែនាំរបស់ក្រុមហ៊ុន។ | ☐ | ☐ |
| | <u>**សុខភាព និងសុវត្ថិភាព**</u> | | |
| 17. | - តើអ្នកឯកភាពទេថា អ្នកត្រូវបង្កើត ផ្តល់ និងអនុវត្ត នូវគោលការណ៍-នីតិវិធីស្តង់ដារលើការអនុវត្តសុខភាព បរិស្ថាន សុវត្ថិភាព និងបទដ្ឋានសំណង់ សម្រាប់បុគ្គលិក កម្មករ និងអ្នកពាក់ព័ន្ធទាំងអស់នៃគម្រោង ព្រោះគ្រោះថ្នាក់ដែលកើតឡើងគ្រប់ពេល ? ហើយប្រសិនបើអ្នកមិនគោរពគោលការណ៍-នីតិវិធីសុវត្ថិភាព អ្នកអនុញ្ញាតឱ្យអង្គការមានសិទ្ធិក្នុងការផាកពិន័យក្នុងតម្លៃ ១០០ដុល្លារអាមេរិក (មួយរយដុល្លារសហរដ្ឋអាមេរិក) មិនរាប់បញ្ចូលពន្ធលើតម្លៃ | ☐ | ☐ |

| | | | |
|---|---|---|---|
| | បន្ថែមក្នុងមួយករណីបន្ទាប់ពីអង្គការចេញលិខិតព្រមានលើកទី៣ ហើយចំនួននេះនឹងត្រូវកាត់ដោយស្វ័យប្រវត្តិពីការទូទាត់នីមួយៗ ?<br>- តើអ្នកដឹងទេថា អ្នកត្រូវបិទបាំងការពារ សុវត្ថិភាពការដ្ឋាន និងការពារការខូចខាតទ្រព្យសម្បត្តិផ្សេងៗពាក់ព័ន្ធនឹងគម្រោង? | | |
| | **<u>ការពន្យាពេលបញ្ចប់គម្រោង, ការងារកែតម្រូវ(Defect) និងការងារធានា និងថែទាំ(Warranty)</u>** | | |
| 18. | - ករណីយឺតយ៉ាវ អ្នកដឹងទេថា អ្នកត្រូវទទួលខុសត្រូវលើការផាកពិន័យ ទាំងការងារជាដំណាក់កាល ឬការងារទាំងមូល ការងារកែតម្រូវ (Defect) ឬការងារធានា (Warranty) ក្នុងអត្រា 0.៥% នៃតម្លៃសរុបទាំងមូលនៃកិច្ចសន្យាក្នុងមួយថ្ងៃ រហូតដល់ដែនកំណត់អតិបរមា ១0% នៃចំនួនសរុបកិច្ចសន្យាបញ្ចូលទាំងពន្ធ ប្រសិនបើមិនមានហេតុផលអាចទទួលយកបាន នៃការយឺតនោះ? ហើយករណីការយឺតយ៉ាវនោះ ចំពោះការងារបន្ទាន់ អ្នកត្រូវជួសជុលភ្លាមបន្ទាប់ពីទទួលបានដំណឹងពីអង្គការ និងមិនឱ្យលើសពី (០៧) ប្រាំពីរថ្ងៃប្រតិទិន និងចំពោះការងារមិនបន្ទាន់មិនត្រូវឱ្យលើស ពី ២០ថ្ងៃនៃថ្ងៃប្រតិទិនទេ បើមិនដូច្នោះ អ្នកឯកភាពឱ្យអង្គការផ្តាច់កិច្ចសន្យាដោយស្វ័យប្រវត្តិ និងឥតលក្ខខណ្ឌ? ហើយអង្គការមានសិទ្ធិគ្រប់គ្រាន់ក្នុងការចាត់ចែងគម្រោង ដោយបញ្ជាទិញ និងរៀបចំផែនការឡើងវិញ ដោយបន្ថែមកម្លាំងពលកម្ម (រកអ្នកផ្គត់ផ្គង់ថ្មី) ឬបន្ថែមកម្លាំងធ្វើការថែមម៉ោង ដើម្បីធានាថាគម្រោងនឹងបញ្ចប់ទាន់ពេល ស្របតាមផែនការដែលបានកំណត់ និងបញ្ចប់ទាន់ពេលតាមកាលវិភាគ ឬតាមវិធីសាស្ត្រផ្សេងទៀតតាមការសម្រេចរបស់អង្គការ ដែលចំណាយទាំងអស់ខាងលើត្រូវទទួលខុសត្រូវដោយអ្នក (កាត់កងពីថវិកាក្នុងគម្រោង) ហើយអ្នកត្រូវទទួលខុសត្រូវចំពោះការធានាទាំងរបស់ការងារថ្មីដែលអង្គការរកថ្មីនោះផងដែរ ?<br>- តើអ្នកបានដឹង និងការពារទេ នូវហានិភ័យផ្សេងៗទាក់ទងនឹងការគ្រប់គ្រងគម្រោង ដូចជា៖ តម្លៃអតិផរណាទី ពន្យារពេលការផ្គត់ផ្គង់សម្ភារ កខ្វះខាតនៃកម្មករ ពិបាកជួលកម្លាំងពលកម្ម ថ្ងៃឈប់សម្រាកសាធារណៈ/ចូលរួមពិធីជប់លៀងអាពាហ៍ពិពាហ៍ និងពិធីសង្គមនានា ការចុះកិច្ចសន្យាបន្តទៅអ្នកសាងសង់ផ្សេងទៀតដែលបង្កើនបណ្តាញទំនាក់ទំនងច្រើនដំណាក់កាល ? | ☐ | ☐ |
| | **<u>ការសម្របសម្រួលនៅការដ្ឋាន</u>** | | |
| 19. | តើអ្នកដឹងទេថា អ្នក ជាអ្នកសម្របសម្រួលជាមួយអ្នកម៉ៅការផ្សេងៗរបស់អង្គការផ្ទាល់ ដែលអង្គការជួលពួកគេឱ្យធ្វើការផ្សេងៗនៅក្នុងគម្រោងជាមួយអ្នក? ដោយអ្នកនឹងផ្គត់ផ្គង់អគ្គិសនី ទឹក រន្ទា ជណ្តើរ ការលើក និងកិច្ចការផ្សេងៗទៀតតាមតម្រូវការដើម្បីបំពេញការងារនីមួយៗ ហើយអ្នកធ្វើការកែតម្រូវនូវបញ្ហាមួយចំនួនដែលបានកើតឡើងក្នុងអំឡុងពេលអ្នកម៉ៅការផ្សេងទៀតកំពុលអនុវត្តការងារនោះផងដែរ ។ រាល់បញ្ហាពាក់ព័ន្ធនឹងបញ្ហាបច្ចេកទេសដូចជា សម្ភារ គំនូសប្លង់ ម៉ោងធ្វើការ កម្មករ ការពន្យាពេល និងបញ្ហាចាំបាច់ផ្សេងទៀតដែលកើតឡើងក្នុងពេលសាងសង់ អ្នកត្រូវដោះស្រាយតាមរចនាសម្ព័ន្ធការងារដែលមានស្រាប់ ? | ☐ | ☐ |
| 20. | តើអ្នកដឹងទេថារាល់ពេល ផ្លាស់ប្តូរអ្នកមើលការនៅការដ្ឋាន អ្នកត្រូវជូនដំណឹងទៅអង្គការ ជាមុនសិនដោយភ្ជាប់ជាមួយនូវ ហេតុផលសមរម្យឱ្យបានច្បាស់លាស់ ហើយក្នុងករណីជ្រើសរើសអ្នកមើលការដ្ឋានថ្មី អ្នកក៏ត្រូវជូនព័ត៌មានមកអង្គការដោយភ្ជាប់មកជាមួយនូវហេតុផល និងឯកសារយោងមួយចំនួន ដើម្បីអង្គការសម្រេច? អង្គការមានសិទ្ធិក្នុងការបដិសេធជ្រើសរើសអ្នកមើលការនៅការដ្ឋាន ដែលមិនមានបទពិសោធន៍ ឬបញ្ហាផ្សេងៗ ។ | ☐ | ☐ |
| 21. | តើអ្នកដឹងទេថា អ្នកត្រូវអនុវត្តតាមការបញ្ជាក់ គំនូសប្លង់ និងឯកសារផ្សេងៗ ក្នុងកិច្ចសន្យា ក្នុងករណីមានចំណុចខ្វះខាត មិនមានឯកសារក្នុងកិច្ចសន្យា ឬអ្នករកឃើញថាមានវិធីសាស្ត្រ ឬបច្ចេកទេសថ្មីដែលអាចសន្សំសំចៃ តែរក្សាគុណភាពនៅដដែល អ្នកអាចស្នើសុំជាផ្លូវការមកអង្គការឱ្យបានមុន ១៤ថ្ងៃ ដើម្បីអង្គការត្រួតពិនិត្យ និងឆ្លើយតបសំណើ? | ☐ | ☐ |
| | **<u>បទពិសោធន៍ការងារ</u>** | | |
| 22. | តើអ្នកមានបទពិសោធន៍សាងសង់អគារដូច ឬប្រហាក់ប្រហែល នឹងគម្រោងនេះដែរ ឬទេ? សូមរៀបរាប់បទពិសោធន៍ការងារដែលមានលក្ខណៈប្រហែលគម្រោងរបស់អង្គការឲ្យបានយ៉ាងតិច ៣ ឆ្នាំចុងក្រោយដោយបញ្ជាក់ឈ្មោះគម្រោង ទីកន្លែង ម្ចាស់គម្រោង តម្លៃគម្រោង និងមានឯកសារជាសំអាងផង (កិច្ចសន្យា, លិខិតបញ្ជាក់, ឬឯកសារណាមួយដែលអាចបញ្ជាក់បាន) ? សម្គាល់៖ សម្រាប់អ្នកដែលមានបទពិសោធន៍សាងសង់គម្រោងអង្គការ(AJF) មិនតម្រូវឲ្យភ្ជាប់ទេ<br>១.<br>..........................................................................................................<br>..........................................................................................................<br>..........................................................................................................<br>.<br>២.<br>..........................................................................................................<br>..........................................................................................................<br>.......................................................................................................... | | |

<table>
<tr><td></td><td>៣.<br>..........................................................................................................................<br>..........................................................................................................................<br>..........................................................................................................................<br>..........................................................................................................................<br>..........................................................................................................................</td><td></td><td></td></tr>
<tr><td colspan="4">យើងខ្ញុំដែលចុះហត្ថលេខាក្រោមនេះ សូមទទួលយកគ្រប់ចំណុចទាំងអស់ដែលបានពិពណ៌នានៅក្នុងទម្រង់ប្រកាសសម្រាប់ការដេញថ្លៃ ។</td></tr>
<tr><td colspan="4">ឈ្មោះអ្នកដេញថ្លៃ: ....................................................<br><br>បោះត្រាក្រុមហ៊ុន និងហត្ថលេខា: .................................................<br><br>មុខងារ: .......................................................<br><br>កាលបរិច្ឆេទ:.................................................................</td></tr>
</table>